ព្រះរាជាណាចក្រកម្ពុជា

ស្ថានទូតព្រះរាជាណាចក្រកម្ពុជា
ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍
តំណាងពាណិជ្ជកម្ម

លេខ ០២-០៤/២០១៥

**ជាតិ សាសនា ព្រះមហាក្សត្រ**

# គោរពជូនលោកជំទាវឯកអគ្គរាជទូត

## របាយការណ៍ស្តីពីពាណិជ្ជកម្មរវាងប្រទេសថៃឡង់ និងកម្ពុជា សម្រាប់ ២០១៤

---

### ស្ថានភាពពាណិជ្ជកម្ម

ប្រភពពីក្រសួងពាណិជ្ជកម្មថៃ បានបង្ហាញថានៅឆ្នាំ ២០១៣ មានទំហំទឹកប្រាក់ពាណិជ្ជកម្មសរុប ៤៧៨ ០០០ លានដុល្លា (ការនាំចូល មាន ២៥០ ០០០ លានដុល្លា និងនាំចេញ ២២៨ ០០០ លានដុល្លា) ។ ប្រៀបធៀបទៅឆ្នាំមុន នៅឆ្នាំ ២០១៤ មានទំហំទឹកប្រាក់ពាណិជ្ជកម្ម ៤៥៥ ០០០ លានដុល្លា ថយចុះប្រមាណជាង ៥% ដោយសារការនាំចូលមានការធ្លាក់ចុះ ៩% (គិតជាទឹកប្រាក់គឺថយ ២២ ០០០ លានដុល្លា) ចំណែកការនាំចេញរក្សាបានទំហំប្រហាក់ប្រហែលតួរលេខឆ្នាំ ២០១៣ (គិតជាទឹកប្រាក់គឺថយ ៥០០ លានដុល្លា)។




*ពាណិជ្ជកម្ម ប្រទេសថៃ ២០១៣ (លានដុល្លា)*




*ពាណិជ្ជកម្ម ប្រទេសថៃ ២០១៤ (លានដុល្លា)*

ផលិតផលសំខាន់ៗ សម្រាប់នាំចេញឆ្នាំ ២០១៣-២០១៤ គឺ ៧៥%ជាផលិតផលឧស្សាហកម្ម (គ្រឿងអេឡិចត្រូនិក រថយន្ត) ១០% ជាផលិតផលកសិកម្ម ៨% ជាផលិតផលកែច្នៃកសិកម្ម និង ៥% ជាផលិតផលរ៉ែ និង ប្រេង ។ ដៃគូរពាណិជ្ជកម្មនាំចេញរបស់ប្រទេសថៃ មានដូចជា ចិន អាមេរិច ជប៉ុន ហុងកុង ម៉ាឡេស៊ី សឹង្ហបុរី ឥណ្ឌូនេស៊ី អូស្ត្រាលី ឥណ្ឌា វៀតណាម ហ្វីលីពីន កូរ៉េ និងបណ្តាប្រទេស នានាជាសមាជិកសហគមអឺរ៉ុប ។ កម្ពុជា ជាដៃគូរទី ១៤ មានទំហំទឹកប្រាក់នាំចេញ ៤៦០០ លានដុល្លា ឆ្នាំ ២០១៤ ។




ផលិតផលនាំចេញរបស់ប្រទេសថៃ ២០១៣ (លានដុល្លា)




ទីផ្សារនាំចេញរបស់ប្រទេសថៃ ២០១៣ (លានដុល្លា)

សម្រាប់ការនាំចូលសេដ្ឋកិច្ចប្រទេសថៃ *ផលិតផលសំខាន់ៗ សម្រាប់នាំចូលឆ្នាំ ២០១៣-២០១៤ គឺ ៤០%ជាវត្ថុធាតុដើមឧស្សាហកម្ម ២៥% ជាទុនគ្រឿងចក្រ ២០% ជាផលិតផលប្រេង និង ១៥% ជាផលិតផលផ្សេងៗ ។ ប្រទេសថៃមានដៃគូរពាណិជ្ជកម្មនាំចូល ដូចជា ជប៉ុន ចិន អារ៉ាប់អេមីរ៉ាត អាមេរិច ម៉ាឡេស៊ី ស្វីស កូរ៉េ សឹង្ហបុរី និង បណ្តាប្រទេស នានាជាសមាជិកសហគមអឺរ៉ុប ។ ដោយប្រៀបធៀបទំហំទឹកប្រាក់នាំចូលមកថៃ មានទឹកប្រាក់ ៥៩០ លានដុល្លា ឆ្នាំ ២០១៤ កម្ពុជា ជាដៃគូរនាំចូលសំខាន់ទី ៤៧ ។*




ដៃគូរនាំចូលរបស់ប្រទេសថៃ ២០១៣ (លានដុល្លា)




ផលិតផលនាំចូល របស់ប្រទេសថៃ ២០១៣ (លានដុល្លា)

យោងតាមតួលេខបានពីក្រសួងពាណិជ្ជកម្មកម្ពុជា ទំហំពាណិជ្ជកម្មកម្ពុជា ជាមួយពិភពលោកសរុប(ការនាំចេញ និងនាំចូល) នៅឆ្នាំ ២០១៤ នេះមានតម្លៃប្រមាណ ១៨,១០០ លានដុល្លា កើន ១៣,៨ ភាគរយធៀបនឹងតម្លៃសរុប ១៥,៩០០ លានដុល្លា កាលពីឆ្នាំមុន។ ទំហំនាំចេញសរុបរបស់កម្ពុជាបានកើន១១,៦ភាគរយ ពី ៦,៩០០ លានដុល្លា ក្នុងឆ្នាំ២០១៣ ដល់ ៧,៧០០ លានដុល្លា នៅឆ្នាំ២០១៤ ខណៈទំហំការនាំចូលសរុបកើនឡើងពី ៩,០០០ លានដុល្លា ក្នុង ២០១៣ ដល់១០,៤០០ លានដុល្លារនៅ ២០១៤ ។

ពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និង ប្រទេសថៃបានបង្ហាញការរីកចំរើនមួយគួរឱ្យកត់សម្គាល់ ។ ជារូបភាពរួម ប្រទេសទាំងពីរមានពាណិជ្ជកម្មសរុបគឺមានអត្រាកំណើន ១១% ដោយមានទំហំទឹកប្រាក់ ៤,៦០០ លានដុល្លា ក្នុងឆ្នាំ ២០១៣ និង ៥,១០០ លានដុល្លា ក្នុងឆ្នាំ ២០១៤ ។ ការនាំចេញរបស់កម្ពុជាមានតម្លៃ ២១៥ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១០ និងបានកើនឡើងដល់ទៅ ៣៥៥ លានដុល្លា នៅឆ្នាំ ២០១៣ និងឈានដល់ ៥៩០ លានដុល្លា នៅឆ្នាំ ២០១៤ ដែលគិតជាភាគរយមាន ៦៦% បើប្រៀបធៀប រវាង ឆ្នាំ ២០១៤- ២០១៣ ។ ប្រទេសថៃគឺជាដៃគូមួយដ៏សំខាន់នាំចូលរបស់កម្ពុជា គឺនៅឆ្នាំ ២០១០ ការនាំចូលរបស់ប្រទេសកម្ពុជាមានតែ ២,៣០០ លានដុល្លារ និងកើនដល់ ៤,២០០ លានដុល្លា នៅឆ្នាំ ២០១៣ ហើយក៏បន្តកើនឡើងដល់ ៤,៦០០ លានដុល្លារ ក្នុងឆ្នាំ ២០១៤ កម្ពុជាបាននាំចូលពីប្រទេសថៃគិតជាភាគរយកើនឡើង ប្រមាណ ១០% បើប្រៀបធៀបទៅនឹង ឆ្នាំ ២០១៣។




*ពាណិជ្ជកម្មនាំចេញនាំចូលប្រទេសថៃ កម្ពុជា ឆ្នាំ ២០១៤ (លានដុល្លា)*

សម្រាប់ការនាំចេញរបស់ថៃ មក កម្ពុជា នៅឆ្នាំ ២០១៤ មានផលិតផលសំខាន់ៗ ១០មុខ គឺប្រេងឥន្ទនៈ គ្រឿងម៉ាស៊ីន គ្រឿងភេសជ្ជៈ សម្ភារ-ផលិតផលសំណង់-ប្លាស្ទិច, ដែក ប្រេងឆា, បន្លែផ្លែឈើ និងផលិតផលក្រណាត់។




*ផលិតផលនាំចេញរបស់ប្រទេសថៃ ទៅកម្ពុជា ឆ្នាំ ២០១៣ (ដុល្លា)*

ដូចគ្នាទៅនឹងឆ្នាំកន្លងទៅនេះ នៅក្នុងឆ្នាំ ២០១៣ កម្ពុជាបាននាំចេញភាគច្រើនគឺដំឡូងមី ពោត ផលិតផលកសិកម្មដទៃទៀត គ្រឿងបន្លាស់អេឡិចត្រូនិក (ម៉ូទ័រ) និងកាកសំណល់ដែកអេតចាយ។ ប៉ុន្តែផលិតផលនាំចេញ របស់កម្ពុជាមានការប្រែប្រួល នៅឆ្នាំ ២០១៤ ដែលផលិតផលសំខាន់ៗគឺ គ្រឿងបន្លាស់អេឡិចត្រូនិក (ម៉ូទ័រ)ផលិតផលកសិកម្ម បន្លែផ្លែឈើ កាកសំណល់ដែកអេតចាយ សម្លៀកបំពាក់ ។




*ផលិតផលនាំចូលរបស់ប្រទេសថៃ ពីកម្ពុជា ឆ្នាំ ២០១៣ (ដុល្លា)*




*ផលិតផលនាំចូលរបស់ប្រទេសថៃ ពីកម្ពុជា ឆ្នាំ ២០១៤ (លានដុល្លា)*

## តំបន់សេដ្ឋកិច្ចពិសេសតាមព្រំដែន

ប្រទេសក្នុងតំបន់មហាអនុតំបន់ទន្លេមេគង្គរួមមាន កម្ពុជា ចិន (ខេត្តយូណាន និង ខេត្តគ័ងស៊ី) ឡាវ មីយ៉ាន់ម៉ា ថៃ និង វៀតណាមបានកំពុងជម្រុញ ពង្រឹងទំនាក់ទំនង វិស័យកិច្ចសហ

ប្រតិបត្តិការទាំង ៧ អោយលេចចេញជារូបរាង តាមកាព្រមព្រៀងចំណាយថវិកាចំនួន ៣០ ពាន់លានដុល្លា (៩៨៦ ពាន់លានបាត) លើគម្រោងអភិវឌ្ឍន៍ គម្រោងផ្លូវគមនាគមន៍ *3Cs* (តភ្ជាប់ផ្លូវគមនាគមន៍ លទ្ធភាពប្រកួតប្រជែង និងសហគមន៍) ផ្តោតលើការតភ្ជាប់ពីប្រទេសមួយទៅមួយទៀតនៅក្នុងរយៈពេល ១០ឆ្នាំ។ មានគម្រោងអាទិភាពពីរ នៃវិស័យកិច្ចសហប្រតិបត្តិការទាំង ៧ មានទំនាក់ទំនងផ្ទាល់នៅតាម ព្រំដែនជាមួយកម្ពុជាគឺ គម្រោងទីមួយ តំបន់សេដ្ឋកិច្ចពិសេសរួមគ្នាចំនួនពីរកន្លែង មួយនៅខេត្តស្រះកែវ និងមួយទៀតនៅខេត្តត្រាត និងគម្រោងទីពីរ ផ្លូវដែកមានល្បឿនលឿន មួយខ្សែ នឹងតភ្ជាប់តំបន់ អារញ្ញប្រថេត ក្នុង ខេត្តស្រះកែវ ទៅ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា។

បាងកកថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០១៥
ទីប្រឹក្សាពាណិជ្ជកម្ម

ហង់ សុជីវិន

**ចម្លងជូនៈ**
ក្រសួងពាណិជ្ជកម្ម